# C105 - Abolition of Forced Labour Convention, 1957 (No. 105)

*Convention concerning the Abolition of Forced Labour (Entry into force: 17 Jan 1959)Adoption: Geneva, 40th ILC session (25 Jun 1957) - Status: Up-to-date instrument (Fundamental Convention).*

## Preamble

The General Conference of the International Labour Organisation,

Having been convened at Geneva by the Governing Body of the International Labour Office, and having met in its Fortieth Session on 5 June 1957, and

Having considered the question of forced labour, which is the fourth item on the agenda of the session, and
Having noted the provisions of the Forced Labour Convention, 1930, and
Having noted that the Slavery Convention, 1926, provides that all necessary measures shall be taken to prevent compulsory or forced labour from developing into conditions analogous to slavery and that the Supplementary Convention on the Abolition of Slavery, the Slave Trade and Institutions and Practices Similar to Slavery, 1956, provides for the complete abolition of debt bondage and serfdom, and

Having noted that the Protection of Wages Convention, 1949, provides that wages shall be paid regularly and prohibits methods of payment which deprive the worker of a genuine possibility of terminating his employment, and

Having decided upon the adoption of further proposals with regard to the abolition of certain forms of forced or compulsory labour constituting a violation of the rights of man referred to in the Charter of the United Nations and enunciated by the Universal Declaration of Human Rights, and

Having determined that these proposals shall take the form of an international Convention,

adopts this twenty-fifth day of June of the year one thousand nine hundred and fifty-seven the following Convention, which may be cited as the Abolition of Forced Labour Convention, 1957:

## Article 1

Each Member of the International Labour Organisation which ratifies this Convention undertakes to suppress and not to make use of any form of forced or compulsory labour--

- (a) as a means of political coercion or education or as a punishment for holding or expressing political views or views ideologically opposed to the established political, social or economic system;
- (b) as a method of mobilising and using labour for purposes of economic development;
- (c) as a means of labour discipline;
- (d) as a punishment for having participated in strikes;
- (e) as a means of racial, social, national or religious discrimination.

## Article 2

Each Member of the International Labour Organisation which ratifies this Convention undertakes to take effective measures to secure the immediate and complete abolition of forced or compulsory labour as specified in Article 1 of this Convention.

## Article 3

The formal ratifications of this Convention shall be communicated to the Director-General of the International Labour Office for registration.

## Article 4

1. This Convention shall be binding only upon those Members of the International Labour Organisation whose ratifications have been registered with the Director-General.

2. It shall come into force twelve months after the date on which the ratifications of two Members hav been registered with the Director-General.

3. Thereafter, this Convention shall come into force for any Member twelve months after the date on whic its ratification has been registered.

### Article 5

1. A Member which has ratified this Convention may denounce it after the expiration of ten years from th date on which the Convention first comes into force, by an act communicated to the Director-General of th International Labour Office for registration. Such denunciation shall not take effect until one year after th date on which it is registered.

2. Each Member which has ratified this Convention and which does not, within the year following th expiration of the period of ten years mentioned in the preceding paragraph, exercise the right o denunciation provided for in this Article, will be bound for another period of ten years and, thereafter, ma denounce this Convention at the expiration of each period of ten years under the terms provided for in thi Article.

### Article 6

1. The Director-General of the International Labour Office shall notify all Members of the International Labour Organisation of the registration of all ratifications and denunciations communicated to him by the Members of the Organisation.

2. When notifying the Members of the Organisation of the registration of the second ratification communicated to him, the Director-General shall draw the attention of the Members of the Organisation to the date upon which the Convention will come into force.

### Article 7

The Director-General of the International Labour Office shall communicate to the Secretary-General of the United Nations for registration in accordance with Article 102 of the Charter of the United Nations full particulars of all ratifications and acts of denunciation registered by him in accordance with the provisions of the preceding Articles.

### Article 8

At such times as it may consider necessary the Governing Body of the International Labour Office shall present to the General Conference a report on the working of this Convention and shall examine the desirability of placing on the agenda of the Conference the question of its revision in whole or in part.

### Article 9

1. Should the Conference adopt a new Convention revising this Convention in whole or in part, then, unless the new Convention otherwise provides:

- (a) the ratification by a Member of the new revising Convention shall ipso jure involve the immediate denunciation of this Convention, notwithstanding the provisions of Article 5 above, if and when the new revising Convention shall have come into force;
- (b) as from the date when the new revising Convention comes into force this Convention shall cease to be open to ratification by the Members.

2. This Convention shall in any case remain in force in its actual form and content for those Members which have ratified it but have not ratified the revising Convention.

### Article 10

The English and French versions of the text of this Convention are equally authoritative.

# អនុសញ្ញាលេខ ១០៥
# ស្តីពី
# ការធ្វើនិរាក្រឹតនៃការងារដោយបង្ខំ[១]

## សន្និសីទសាកលនៃអង្គការអន្តរជាតិខាងការងារ

បានឃើញការកោះប្រជុំនៅហ្សឺណែវ ដោយក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ និងបានបើកសម័យប្រជុំលើកទីសែសិបរបស់ខ្លួននាថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៥៧។

បានឃើញថាបញ្ហាការងារដោយបង្ខំ គឺជាបញ្ហាដែលត្រូវយកមកពិភាក្សាក្នុងចំណុចទីបួន ក្នុងរបៀបវារៈនៃសម័យប្រជុំនេះ។

បានឃើញបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញាឆ្នាំ១៩៣០ ស្តីពីការងារដោយបង្ខំ។

បានឃើញអនុសញ្ញាឆ្នាំ១៩២៦ ស្តីពីទាសភាពដែលមានចែងអំពីវិធានការចាំបាច់ទាំងឡាយសម្រាប់បង្ការមិនឱ្យមានការងារដោយបង្ខំ ឬការងារជាកាតព្វកិច្ចដែលមានលក្ខណៈដូចគ្នានឹងអំពើទាសភាព និងបានឃើញអនុសញ្ញាបំពេញបន្ថែមឆ្នាំ១៩៥៦ ស្តីពីការធ្វើនិរាក្រឹត្យរបបទាសភាពដែលចែងអំពីការធ្វើនិរាក្រឹត្យទាំងស្រុងនូវបំណុលជាខ្ញុំបំរើ។

បានឃើញអនុសញ្ញាឆ្នាំ១៩៤៩ ស្តីពីការគាំពារប្រាក់ឈ្នួលដែលចែងថាប្រាក់ឈ្នួលត្រូវតែបើកឱ្យបានទៀងទាត់ ហើយត្រូវហាមឃាត់មិនឱ្យមានរបៀបបើកប្រាក់ទាំងឡាយដែលជាហេតុធ្វើឱ្យកម្មករនិយោជិតចង់បញ្ឈប់ការងាររបស់ខ្លួនដោយឯកឯង។

បានឃើញការយល់ព្រមចំពោះសំណើបន្ថែមនានាដែលពាក់ព័ន្ធនឹងការធ្វើនិរាក្រឹត្យលើទម្រង់មួយចំនួននៃការងារដោយបង្ខំ ឬការងារជាកាតព្វកិច្ចដែលនឹងនាំឱ្យឈានទៅដល់ការរំលោភសិទ្ធិមនុស្សដូចចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ និងដែលបានប្រកាសដោយសេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្ស។

បានកំណត់ថាសំណើទាំងនេះគួរត្រូវមានទម្រង់ជាអនុសញ្ញាអន្តរជាតិ អនុម័តនៅថ្ងៃទីម្ភៃប្រាំ ខែមិថុនា ឆ្នាំមួយពាន់ប្រាំបួនរយហាសិបប្រាំពីរ នូវអនុសញ្ញាដូចខាងក្រោមដែលតទៅហៅថា អនុសញ្ញាឆ្នាំ១៩៥៧ ស្តីពីការធ្វើនិរាក្រឹត្យនៃការងារដោយបង្ខំ៖

---

១. កាលបរិច្ឆេទចូលជាធរមាន ៖ ថ្ងៃទី ១៧ មករា ឆ្នាំ១៩៥៩

## មាត្រា ១

ប្រទេសជាសមាជិកនីមួយៗនៃអង្គការអន្តរជាតិខាងការងារ ដែលផ្ដល់សច្ចាប័នលើអនុសញ្ញានេះ ត្រូវយល់ព្រមធ្វើការហាមប្រាម និងមិនត្រូវប្រើប្រាស់នូវទម្រង់នៃការងារណាដែលមានលក្ខណៈជាការងារដោយបង្ខំ ឬការងារជាកាតព្វកិច្ចមានជាអាទិ៍ការងារះ

(ក) ដែលប្រើប្រាស់សម្រាប់ជាមធ្យោបាយនៃការបង្ខិតបង្ខំខាងនយោបាយ ឬការអប់រំខាងនយោបាយ ឬក៏ជាការដាក់ទណ្ឌកម្មដើម្បីឱ្យសម្ដែងចេញ ឬប្រកាន់យកទស្សនៈនយោបាយ ឬមនោគមវិជ្ជាសំដៅប្រឆាំងទល់នឹងប្រព័ន្ធនយោបាយ ប្រព័ន្ធសង្គម ឬក៏ប្រព័ន្ធសេដ្ឋកិច្ចដែលមានរួចហើយ។

(ខ) ដែលប្រើជាវិធីមួយដើម្បីកេណ្ឌប្រមូល និងប្រើប្រាស់កម្លាំងពលកម្មសម្រាប់ជាគោលដៅនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច។

(គ) ដែលប្រើជាមធ្យោបាយនៃការដាក់វិន័យការងារ។

(ឃ) ដែលប្រើសម្រាប់ជាការដាក់ទណ្ឌកម្មដោយសារការចូលរួមក្នុងកូដកម្ម។

(ង) ដែលប្រើជាមធ្យោបាយនៃការរើសអើងខាងពូជសាសន៍ សង្គម សញ្ជាតិ ឬសាសនា។

## មាត្រា ២

ប្រទេសជាសមាជិកនីមួយៗនៃអង្គការអន្តរជាតិខាងការងារ ដែលបានផ្ដល់សច្ចាប័នអនុសញ្ញានេះ ត្រូវចាត់វិធានការឱ្យមានប្រសិទ្ធិភាព ដើម្បីធានាដល់ការធ្វើនិរាក្រឹត្យជាបន្ទាន់ និងពេញលេញនូវការងារដោយបង្ខំ ឬការងារជាកាតព្វកិច្ចដូចដែលមានចែងក្នុងមាត្រា ១ នៃអនុសញ្ញានេះ។

## មាត្រា ៣

ការផ្ដល់សច្ចាប័នជាផ្លូវការនៃអនុសញ្ញានេះ ត្រូវជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារដើម្បីចុះបញ្ជិកា។

១. អនុសញ្ញានេះ ត្រូវអនុវត្តចំពោះតែសមាជិកទាំងឡាយនៃអង្គការអន្តរជាតិខាងការងារ ដែលការផ្ដល់សច្ចាប័នរបស់ខ្លួន ត្រូវបានទទួលការចុះបញ្ជិកាពីអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងាររួចហើយ។

២. អនុសញ្ញានេះ ត្រូវចូលជាធរមានក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្ដល់សច្ចាប័នរបស់ប្រទេសជាសមាជិកចំនួនពីរត្រូវបានទទួលការចុះបញ្ជិកាពីអគ្គនាយកនៃការិយាល័យអង្គការអន្តរជាតិខាងការងាររួចហើយ។

៣. បន្ទាប់ពីនោះមក អនុសញ្ញានេះត្រូវចូលជាធរមានសម្រាប់ប្រទេសជាសមាជិកណាមួយក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់ប្រទេសនោះបានទទួលការចុះបញ្ជិការរួចហើយ។

## មាត្រា ៥

១. ប្រទេសជាសមាជិកណាមួយដែលបានផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះរួចហើយអាចធ្វើអប្បដិបត្តិកម្មវិញបាននៅក្នុងឆ្នាំបន្ទាប់ពីអំឡុងពេលដប់ឆ្នាំបានកន្លងផុតដោយគិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានលើកទីមួយ នៃអនុសញ្ញានេះតាមរយៈលិខិតជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារដើម្បីអគ្គនាយកនេះចុះបញ្ជិកា។ អប្បដិបត្តិកម្មនេះ នឹងមិនមានអនុភាពទេរហូតរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកា។

២. ប្រទេសជាសមាជិកណាដែលបានផ្តល់សច្ចាប័នអនុសញ្ញានេះរួចហើយ ប៉ុន្តែនៅក្នុងឆ្នាំបន្ទាប់ពីការផុតរលត់នៃរយៈពេលដប់ឆ្នាំ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើមិនបានអនុវត្តសិទ្ធិនៃអប្បដិបត្តិកម្មដូចដែលបានកំណត់ក្នុងមាត្រានេះទេ នឹងត្រូវរង់ចាំក្នុងរយៈពេលដប់ឆ្នាំថ្មីជាបន្តទៀត។ ហើយបន្ទាប់ពីនោះមកអាចធ្វើអប្បដិបត្តិកម្ម ក្រោយការកន្លងផុតទៅនៅរៀងរាល់រយៈពេលដប់ឆ្នាំតាមន័យនៃមាត្រានេះ។

## មាត្រា ៦

១. អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវជូនដំណឹងទៅគ្រប់ប្រទេសជាសមាជិកទាំងអស់នៃអង្គការអន្តរជាតិខាងការងារអំពីការចុះបញ្ជិកានៃរាល់ការផ្តល់សច្ចាប័ន និងអប្បដិបត្តិកម្មរបស់ប្រទេសជាសមាជិកនានានៃអង្គការនេះ។

២. នៅពេលជូនដំណឹងអំពីការផ្តល់សច្ចាប័នទីពីរលើអនុសញ្ញានេះ អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវក្រើនរំលឹកចំពោះប្រទេសជាសមាជិកទាំងអស់នូវកាលបរិច្ឆេទដែលអនុសញ្ញានេះនឹងត្រូវចូលជាធរមាន។

## មាត្រា ៧

អនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវផ្ញើជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដើម្បីចុះបញ្ជិកានូវរបាយការណ៍លំអិតអំពីការផ្តល់សច្ចាប័ន និងលិខិតធ្វើអប្បដិបត្តិកម្មដែលបានចុះបញ្ជិកានូវរបាយការណ៍លំអិតអំពីការផ្តល់សច្ចាប័ន និងលិខិតធ្វើអប្បដិបត្តិកម្មដែលបានចុះបញ្ជិកាដោយអគ្គនាយកនេះរួចហើយ ស្របតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃមាត្រាខាងលើ។

## មាត្រា ៨

នៅពេលណាដែលពិនិត្យឃើញថា មានការចាំបាច់ក្រុមប្រឹក្សាភិបាលនៃអង្គការអន្តរជាតិខាងការងារ ត្រូវដាក់ជូនសន្និសីទសាកលនូវរបាយការណ៍ស្តីពីដំណើរប្រព្រឹត្តទៅនៃអនុសញ្ញានេះ ព្រមទាំងបញ្ជាក់ពីគោលបំណងនៃការបញ្ចូលទៅក្នុងរបៀបវារៈនៃសន្និសីទនេះនូវបញ្ហាពាក់ព័ន្ធ នឹងការធ្វើបុនរាព្រឹត្តទាំងស្រុង ឬដោយផ្នែកខ្លះចំពោះអនុសញ្ញានេះ។

## មាត្រា ៩

១. ក្នុងករណីដែលសន្និសីទសាកល អនុម័តអនុសញ្ញាថ្មីដែលធ្វើបុនរាព្រឹត្តទាំងស្រុង ឬដោយផ្នែកចំពោះអនុសញ្ញានេះ និងវៀរលែងតែអនុសញ្ញាថ្មីនោះមានកំណត់បទប្បញ្ញត្តិផ្សេងពីនេះ៖

(ក) ការផ្តល់សច្ចាប័ននៃសមាជិកណាមួយចំពោះអនុសញ្ញាថ្មីដែលបានធ្វើបុនរាព្រឹត្តហើយនោះ នឹងត្រូវមានន័យពេញលេញតាមច្បាប់ថា ប្រទេសជាសមាជិកនោះបានធ្វើអប្បដិបត្តិកម្មចំពោះអនុសញ្ញានេះជាស្វ័យប្រវត្តិដោយមិនមានគិតដល់បទបញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ ខាងលើ និងប្រសិនបើក្នុងពេលនោះអនុសញ្ញាថ្មីនេះ ត្រូវបានចូលជាធរមានរួចហើយ។

(ខ) ចាប់ពីពេលដែលអនុសញ្ញាបុនរាព្រឹត្តថ្មីនោះចូលជាធរមានអនុសញ្ញានេះនឹងលែងបើកឱ្យប្រទេសជាសមាជិកនានាផ្តល់សច្ចាប័នទៀតហើយ។

២. ទោះក្នុងករណីណាក៏ដោយ អនុសញ្ញានេះនឹងនៅជាធរមានជាដរាបទាំងទម្រង់និងខ្លឹមសារ ចំពោះប្រទេសជាសមាជិកណាដែលបានឱ្យសច្ចាប័នរួចហើយ ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញាបុនរាព្រឹត្តនៅឡើយ។

## មាត្រា ១០

អត្ថបទបកប្រែជាភាសាអង់គ្លេស និងបារាំងនៃអនុសញ្ញានេះមានតម្លៃជាផ្លូវការដូចគ្នា។

********************